# កិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ ២០០៨ និងទិសដៅ ឆ្នាំ២០០៩
# នៃវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍

កិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ ២០០៨ និងទិសដៅ ឆ្នាំ២០០៩ នៃវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ បានប្រារព្ធឡើងកាលពីថ្ងៃទី០៩ ខែមេសា ឆ្នាំ ២០០៩ នៅទីស្តីការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **សូរ ឃុន** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងដោយមានការចូលរួមពីថ្នាក់ដឹកនាំក្រសួងសមាជិក សមាជិកា និងតំណាងក្រុមហ៊ុនជាដៃគូយ៉ាងច្រើនកុះករ ។

ក្នុងឱកាសនោះ ឯកឧត្តម **សារ៉ាត់ ខាន់** រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានបង្ហាញអំពីការពិនិត្យលទ្ធផលការងារឆ្នាំ២០០៨ និងទស្សនវិស័យនៃការអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ឆ្នាំ ២០០៩-២០១៣ និងការធ្វើបទអន្តរាគមន៍របស់ក្រុមហ៊ុនជាដៃគូជាច្រើនរូបទៀតផង ។

ឯកឧត្តមរដ្ឋមន្ត្រី **សូរ ឃុន** បានថ្លែងថា គោលដៅជាយុទ្ធសាស្ត្ររបស់ក្រសួង គឺការបន្តរៀបចំប្រព័ន្ធប្រៃសណីយ៍ និងទូរគមនាគមន៍ ឱ្យមានការរីកចំរើន ដូចបណ្តាប្រទេសនៅក្នុងតំបន់ និងអន្តរជាតិ ទាំងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងសេវាបន្ថែមទៀតដែលមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់សេវាកម្មទំនើប គ្របដណ្តប់ទូទាំងប្រទេស សំដៅចូលរួមជំរុញដំណើរសេដ្ឋកិច្ច លើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ។ ពង្រីកសេវាកម្មទៅដល់តំបន់ជនបទ បង្កលក្ខណៈឱ្យប្រជាជនបានទទួលព័ត៌មាន និងបញ្ជូនព័ត៌មានក្នុងការទាក់ទងគ្នាបានយ៉ាងឆាប់រហ័ស ។ បង្កើនកិច្ចសហប្រតិបត្តិការលើកទឹកចិត្តវិនិយោគឯកជនចូលរួមសំរេចនូវកម្មវិធីទំនើបកម្មវិស័យនេះ ។ យកចិត្តទុកដាក់ជំរុញការងារបណ្តុះបណ្តាលធនធានមនុស្ស ។

ទាក់ទិននិងវិស័យប្រៃសណីយ៍ ឯកឧត្តមរដ្ឋមន្ត្រីបានបញ្ជាក់ថា សេវាបញ្ជូននិងទទួលបញ្ញើក្នុងប្រទេសអនុវត្តបានពី ៥ទៅ៦ជើងក្នុង១សប្តាហ៍ និងទៅអន្តរជាតិបាន៥ជើងតាមជើងយន្តហោះក្នុង១សប្តាហ៍ ។ ការប្តូរបញ្ញើផ្ទៃរាបអន្តរជាតិតាមច្រកប៉ោយប៉ែតខេត្តបន្ទាយមានជ័យជាមួយប្រៃសណីយ៍ថៃ និងបាវិត ខេត្តស្វាយរៀងជាមួយប្រៃសណីយ៍ប្រទេសវៀតណាមបានពី៣ទៅ៤ជើងក្នុង១ខែ ។ បង្កើតឱ្យមានសេវាអាណត្តិប្រៃសណីយ៍ក្នុងប្រទេស និងអន្តរជាតិ ការផ្ញើប្រាក់តាមទូរស័ព្ទអេឡិចត្រូនិច និងបញ្ញើផ្សព្វផ្សាយពាណិជ្ជកម្ម ។ សេវាបញ្ញើឆាប់រហ័សបាន និងកំពុងដំណើរការ២៤ខេត្ត-ក្រុង ៧សាខានៅភ្នំពេញ១៦ស្រុក និងបញ្ជូនទៅអន្តរជាតិបាន២ជើងក្នុង១ថ្ងៃ ។ ដាក់ឱ្យប្រើប្រាស់ប្រព័ន្ធត្រួតពិនិត្យបញ្ញើតាមប្រព័ន្ធ IPS ជាមួយអន្តរជាតិនៅភ្នំពេញ ៣កន្លែង និង៥កន្លែងនៅតាមខេត្ត គឺខេត្តសៀមរាប បាត់ដំបង បន្ទាយមានជ័យ ពោធិ៍សាត់ និងកំពង់ឆ្នាំង ។ បានផ្តល់អាជ្ញាប័ណ្ណសេវាឆាប់រហ័សអន្តរជាតិដល់ក្រុមហ៊ុនចំនួន១៧ ដែលកំពុងធ្វើសេវាកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ជាមធ្យមអត្រានៃការប្រើប្រាស់សេវាប្រៃសណីយ៍នៅភ្នំពេញគឺស្មើនឹង១.៧០ និងខេត្តស្មើ0.0៣ ក្នុងប្រជាពលរដ្ឋ ១នាក់ ក្នុង១ឆ្នាំ ។ ក្នុងអត្រានេះ អត្រាប្រើប្រាស់សេវាបញ្ញើអន្តរជាតិស្រូបយកប្រមាណ៩២%នៃសេវាទូទាំងប្រទេស ។ ឯកឧត្តមរដ្ឋមន្ត្រីក៏បានលើកឡើងផងដែរ អំពីសេវាទូរគមនាគមន៍ថា គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០៨ អត្រាប្រើប្រាស់ទូរស័ព្ទចល័តនិងអចល័តស្មើ២៤.៧១ សំរាប់ប្រជាពលរដ្ឋ១០០នាក់ស្មើនឹង៤៣.៤១៧គ្រឿង ។
ទូរស័ព្ទចល័តស្មើនឹង២៤.៤៣សំរាប់ប្រជាពលរដ្ឋ១០០នាក់ ស្មើនឹង៣,៧៩១,៨៤៣គ្រឿង ។

- ទូរគមនាគមន៍កម្ពុជា និងបណ្តាក្រុមហ៊ុនជាដៃគូអាជីវកម្មជាមួយក្រសួងបានដាក់ឱ្យប្រើប្រាស់ទូរស័ព្ទចល័ត និងអចល័តសរុបចំនួន៣,៨៣៥,២៥១គ្រឿង និងទូរស័ព្ទសាធារណៈចំនួន៤៥៦គ្រឿង ។

- សេវាអ៊ិនធឺណិតមានចំនួន៩ក្រុមហ៊ុនដោយមានអតិថិជនសរុប ២០,១០៨នាក់ ។

- ផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនជាតិ និងអន្តរជាតិក្នុងការធ្វើអាជីវកម្មទូរស័ព្ទចល័ត-អចល័ត និងសេវាមួយចំនួនទៀតដូចជាសេវាទូរស័ព្ទតាមប្រព័ន្ធ Internet (ISP) និងសេវា (VoIP) ។

គុណភាពបណ្តាញ និងសេវាត្រូវបានពង្រឹងឥតឈប់ឈរ ។ ប្រភេទទូរស័ព្ទអចល័តមានការអភិវឌ្ឍន៍ពង្រីកការប្រើប្រាស់ជាបន្តបន្ទាប់ជាពិសេសនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តដែលមានបណ្តាញកាប្លិ៍អុបទិក ។ រីឯប្រភេទទូរស័ព្ទចល័តវិញបានគ្របដណ្តប់ដល់ទីប្រជុំជន និង ទីជនបទក្នុងអត្រាពី៦0 ទៅ ៨0 ភាគរយ ។

ឯកឧត្តមរដ្ឋមន្ត្រី **សូរ ឃុន** បានបន្តទៀតថា ពាក់ព័ន្ធនឹងកិច្ចអភិវឌ្ឍន៍ទូរគមនាគមន៍ជនបទក្រសួងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការជំរុញអនុវត្តគំរោង៣ដោយប្រើប្រាស់ប្រាក់កំចី និងការវិនិយោគបរទេស ។

- **គំរោងទី១** បណ្តាញទូរគមនាគមន៍មហាអនុតំបន់ទន្លេមេគង្គរបស់ JIBC បានឈានដល់ការចុះកិច្ចសន្យាធ្វើជាដៃគូផ្គត់ផ្គង់សេវាទីប្រឹក្សារៀបចំឯកសារពាក់ព័ន្ធដាក់ឱ្យធ្វើការដេញថ្លៃ ។

- **គំរោងទី២** ការស្ថាបនាបណ្តាញទូរគមនាគមន៍ព័ត៌មាន ឆ្លងកាត់មហាអនុតំបន់ទន្លេមេអង្គ GMS - IS សំរាប់ដំណាក់កាលទី១ បានអនុវត្តស្ទើរតែចប់ជាស្ថាពរហើយទាំងការជីករាយ បណ្តាញកាប្លិ៍ពីស្គន់ទៅសៀមរាប ។ ដំណាក់កាលទី២មានការជីករាយដាក់បណ្តាញកាប្លិ៍អុបទិកពីខេត្តកំពង់ចាមដល់ខេត្តស្ទឹងត្រែងព្រំប្រទល់ប្រទេសឡាវ ក៏បានបញ្ចប់រួចរាល់ហើយដែរ ។

- **គំរោងទី៣** ការកសាងហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ក្នុងប្រទេស ដោយប្រើបណ្តាញកាប្លិ៍អុបទិកជាការវិនិយោគរបស់ក្រុមហ៊ុន CFOCN ក្នុងគំរោងជីកកប់កាប្លិ៍ប្រវែង៨,៥៨៣គីឡូម៉ែត្រ ដោយក្នុងដំណាក់កាលទី១ សំរេចបានការជីករាយបណ្តាញកាប្លិ៍ក្នុងដីរួចហើយ ដោយមានប្រវែង២000គីឡូម៉ែត្រតាមផ្លូវជាតិលេខ១ លេខ ២ លេខ ៤ លេខ ៥ លេខ ៦ និងរាជធានីភ្នំពេញ ។

នៅល្ងាចថ្ងៃដដែលពិធីសន្និបាតប្រចាំឆ្នាំក៏បានចាប់ផ្តើមបន្ត ដើម្បីបូកសរុបលទ្ធផលការងារឆ្នាំ២00៨ និងទិសដៅឆ្នាំ២00៩ ហើយក៏មានការបំពាក់មេដាយ សុវត្ថារា ជូនមន្ត្រីរាជការចំនួន៣៥រូប ក្នុងនោះមានថ្នាក់ធិបឌិន្ទចំនួន១៣រូប ថ្នាក់សេនាចំនួន៨រូប និងថ្នាក់អស្សឫទ្ធិចំនួន១៤រូបទៀតផង ។ ដោយឡែកមន្ត្រីរាជការចំនួន៨៣រូបផ្សេងទៀតដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិក៏ទទួលបានមេដាយការងារដែរ ក្នុងនោះមេដាយមាសការងារចំនួន២១រូប មេដាយប្រាក់ការងារចំនួន៥៣រូប និងមេដាយសំរិទ្ធិការងារចំនួន៩រូប ។